# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិ ប្រយុទ្ធនឹងជំងឺអេដស៍
នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ

## កំណត់ហេតុ
## កិច្ចប្រជុំការងារបច្ចេកទេសប្រចាំសប្តាហ៍

### ថ្ងៃ ច័ន្ទ ទី១៥ ខែ មិថុនា ឆ្នាំ ២០១៥ នៅសាលប្រជុំ អ.ជ.ប.ជ.អ

នៅវេលាម៉ោង ៩:០០ នាទីព្រឹក ថ្ងៃច័ន្ទ ទី១៥ ខែ មិថុនា ឆ្នាំ២០១៥ អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានរៀបចំកិច្ចប្រជុំការងារបច្ចេកទេសប្រចាំសប្តាហ៍ របស់ខ្លួនក្រោមការដឹកនាំកិច្ចប្រជុំដោយឯកឧត្តមវេជ្ជបណ្ឌិត តែង គន្ធី អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការចូលរួមពីអគ្គលេខាធិការរង ប្រធាន និងអនុប្រធាននាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋាន។

**១. សមាសភាពចូលរួម:**

សមាសភាពចូលរួមក្នុងកិច្ចប្រជុំថ្ងៃនេះ មានអគ្គលេខាធិការ អគ្គលេខាធិការរង ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន សរុបទាំងអស់ចំនួន ១៨ រូប (មានភ្ជាប់ជូនបញ្ជីវត្តមានចូលរួម)។

**២. អវត្តមាន** ( ៣ រូប )

ឯឧ. អាំង សំបូរ (ច្បាប់)
ឯឧ. ជា ប៉ោ (ច្បាប់)
លោកវេជ្ជ. ជ វ៉ានី

**៣. ប្រធានបទនៃកិច្ចប្រជុំ**

- របាយការណ៍សកម្មភាពសំរាប់សប្តាហ៍កន្លងមកនិងសកម្មភាពសំរាប់សប្តាហ៍បន្ទាប់របស់នាយកដ្ឋាននីមួយៗ
- សំណូមពររួម និងផ្សេងៗ
- ការណែនាំរបស់អគ្គលេខាធិការតាមនាយកដ្ឋាន

## ៤. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ

ជាកិច្ចចាប់ផ្តើមនៃអង្គប្រជុំ ឯកឧត្តមវេជ្ជ. តែង គន្ធី អគ្គលេខាធិការ អាជ្ញាធរជាតិយុទ្ធនឹងជំងឺអេដស៍ មានមតិស្វាគមន៍ចំពោះ ឯកឧត្តម លោក លោកស្រី អគ្គលេខាធិការរង ប្រធាន និងអនុប្រធាននាយកដ្ឋានទាំងអស់ ដែលបានចូលរួមក្នុងកិច្ចប្រជុំនាព្រឹកនេះ ។ ក្នុងឱកាសនេះដែរ ឯកឧត្តមប្រធានអង្គប្រជុំ បានធ្វើការពិនិត្យទៅលើ របាយការណ៍សកម្មភាពការងារក្នុងសប្តាហ៍កន្លងមក ព្រមទាំងបានផ្តល់ណែនាំដល់នាយកដ្ឋាន PMERD ក្នុងការរៀបចំរបាយការណ៍ប្រចាំសប្តាហ៍អោយកាន់តែប្រសើរឡើង។ ឆ្លងចូលដល់ប្រធានបទទី១ ឯកឧត្តមប្រធានអង្គប្រជុំ ក៏បានប្រគល់វេទិកាទៅនាយកដ្ឋាននីមួយៗដើម្បីធ្វើរបាយការណ៍សកម្មភាព ដែលបានអនុវត្តនៅសប្តាហ៍កន្លងមក និងផែនការសកម្មភាពសំរាប់អនុវត្តសប្តាហ៍បន្ទាប់ទៀតដូចខាងក្រោម ៖

### ៤.១.នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតំលៃ និងស្រាវជ្រាវ

លោកវេជ្ជ. រស់ សីលវ៉ាត់ អគ្គលេខាធិការរង និងជាប្រធាននាយកដ្ឋានPMER បានរាយការណ៍ជូនអង្គប្រជុំទាក់ទងនឹងការងារ ដែលបានអនុវត្តក្នុងសប្តាហ៍កន្លងមក និងសកម្មភាពសំរាប់អនុវត្តក្នុងសប្តាហ៍បន្ទាប់រួមមាន៖

- បានបញ្ចប់របាយការណ៍ GARPR និង ដាក់បញ្ចូលទៅOnline រួចរាល់។
- បានរៀបចំរបាយការណ៍សិក្ខាសាលា validation on NSP IV ហើយបានដាក់ជូនថ្នាក់ដឹកនាំពិនិត្យរួចរាល់។
- ទើបបានទទួលរបាយការណ៍សេចក្តីព្រៀងNSP IV ពីទីប្រឹក្សាបច្ចេកទេស និងបន្តធ្វើការកែសម្រួលពិនិត្យបន្ថែមទៀត។
- បានចាត់តាំងមន្ត្រីបង្គោល (លោកវេជ្ជ.លី ចាន់វ៉ារុធ)ទទួលបន្ទុកការងារធ្វើបច្ចុប្បន្នភាពUpdate Situation។
- បានចូលរួមកិច្ចប្រជុំCAM-Info ស្តីពីតួនាទី ភារកិច្ចរបស់មន្ត្រី ដើម្បីជំនួសមន្ត្រីដែលចូលនិវត្តន៍។
- បានចុះបេសកកម្មនិងរាយការណ៍ពីលទ្ធផលដែលទទួលបានក្នុងពេលអនុវត្តការងារនៅខេត្តកំពង់ស្ពឺ ។
- បានរៀបចំកិច្ចប្រជុំការងារបច្ចេកទេសប្រចាំនាយកដ្ឋាន**PMER**ដើម្បីធ្វើការពិនិត្យទៅលើសកម្មភាពបច្ចុប្បន្នភាពរបស់នាយកដ្ឋាន និងបានបែងចែកតួនាទី និងការទទួលខុសត្រូវរបស់មន្ត្រីនៅក្នុងនាយកដ្ឋាន។
- បានចាត់តាំងមន្ត្រីទៅចូលរួមប្រជុំក្រុមការងារប្រឆាំងការជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ ស្តីពីការរៀបចំឯកសារលទ្ធផលនៃកិច្ចប្រជុំ SOM 10 and IMM4 ។

### ៤.២. នាយកដ្ឋាន បង្ការ ថែទាំ និង គាំទ្រ

លោកវេជ្ជ. វ៉ុង យ៉ាណាត ប្រធាននាយកដ្ឋាន បង្ការ ថែទាំ និង គាំទ្រ បានរាយការណ៍ ជូនអង្គប្រជុំទាក់ទងនឹងការងារដែលបាន អនុវត្តក្នុងសប្តាហ៍កន្លងមក និងសកម្មភាពសំរាប់អនុវត្តក្នុងសប្តាហ៍បន្ទាប់ ដែលក្នុងនោះរួមមានដូចខាងក្រោម៖

- បានអមដំណើរឯកឧត្តម ទា ផលា ក្នុងការចុះផ្សព្វផ្សាយអប់រំអ្នកផ្ទុកមេរោគអេដស៍ និងសិស្សសាលានាខេត្តបាត់ដំបង ស្តីអំពីការលប់បំបាត់ការរើសអើង ម៉ាក់ងាយខ្លួនឯង(Sell-Sigma Discrimination ) ព្រមទាំងបានរាយការណ៍ពីលទ្ធផល និងសកម្មភាពការងារដែលបានអនុវត្ត។
- បានពិនិត្យលើនិងកែសម្រួល លើផែនការសកម្មភាពការងារប្រចាំនាយកដ្ឋាន ក្រោមជំនួយរបស់មូលនិធិសកល។

## ៥. សកម្មភាពក្នុងសប្តាហ៍បន្ទាប់:

### ៥.១. នាយកដ្ឋាន ផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ៖

- បន្តពិនិត្យលើសេចក្តីព្រៀងNSP IV ដែលទទួលបានពីទីប្រឹក្សាបច្ចេកទេសនិងបន្តធ្វើការកែសម្រួលពិនិត្យបន្ថែមទៀត។
- បន្តពិនិត្យបច្ចុប្បន្នភាព Update Situation ។

## ៦. សំណូមពររួម និងផ្សេងៗ

- លោកវេជ្ជ. លោកវេជ្ជ. វ៉ុង យ៉ាណាត ស្នើសុំលោកប្រធានអង្គប្រជុំ ក្នុងការលើកពេលចុះបេសសកម្មទៅខែបន្ទាប់វិញ។
- លោកវេជ្ជ.រស់ សីលវ៉ាត់ ស្នើសុំបញ្ជីសារពើព័ណ្ឌ សម្រាប់នាយកដ្ឋានPMERD ដើម្បីធ្វើការពិនិត្យនិងថែរក្សា អ្វីដែលមានក្នុងនាយកដ្ឋាន។ ព្រមទាំងស្នើសុំអោយមានការចាត់ វិធានការនិងស្វែងរកដំណោះស្រាយចំពោះករណីCPU របស់លោកកែវ ចំណាន ក្នុងនាយកដ្ឋាន។
- ឯ.ឧ ឈឹម ឃិនដារ៉េត ស្នើសុំអោយលោក ហេង ហង់វិបុល ទទួលការងារផ្នែកហិរញ្ញវត្ថុ បន្តពីTA អាស្រ័យដោយTA នឹងត្រូវបញ្ចប់កិច្ចសន្យាការងារក្នុងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៥ ខាងមុខនេះ រហូតដល់មានTA ថ្មី។ ចំណែក PAB នឹងមានកិច្ចប្រជុំផ្ទៃក្នុងដើម្បីចាត់តាំងមន្ត្រីទទួលខុសត្រូវទាំងផ្នែកបច្ចេកទេស និងថវិកា។

**៧. មតិណែនាំ លើការៈកិច្ចសប្តាហ៍បន្ទាប់ របស់ឯ.ឧ.អគ្គលេខាធិការ ៖**

- ស្នើគ្រប់នាយកដ្ឋាន ពេលចុះបេសសកម្ម ត្រូវរៀបចំលិខិតសុំជួបដល់មន្ត្រីដែលទទួលខុសត្រូវ នៅថ្នាក់មូលដ្ឋាន។
- នាយកដ្ឋានPMER ត្រូវរៀបចំអោយមានជាឯកសារGARPR សម្រាប់ធ្វើការដាក់បញ្ចូលUpload និងសម្រាប់បកប្រែ។
- នាយកដ្ឋានPMER ត្រូវរៀបចំធ្វើបទបង្ហាញរបាយការណ៍វឌ្ឍនភាព និងសមិទ្ធិផលស្តីពីការឆ្លើយតបទូលំទូលាយនិងពហុវិស័យទៅនឹង ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍៦ខែ(ឆមាស) ឆ្នាំ២០១៥ ក្នុងកិច្ចប្រជុំ PAB ដែលនឹងប្រារព្ធធ្វើ នៅថ្ងៃទី៣០ ខែមិថុនា ២០១៥។
- សម្រាប់របាយការណ៍ នាយកដ្ឋានPMER ដែលលើសពី២ទំព័រ ត្រូវមានហត្ថលេខាបំព្រួញ របស់មន្ត្រីទទួលបន្ទុក។
- ប្រធាននាយកដ្ឋានPMER ត្រូវរៀបចំបញ្ជីសារពើព័ណ្ឌជាក់ស្តែង ហើយផ្ញើជូន លោក ហុងលី ដើម្បីធ្វើការផ្ទៀងផ្ទាត់ និងជូនដំណឹងទៅរដ្ឋបាលដើម្បីធ្វើការដោះស្រាយជាបន្ត ។
- នាយកដ្ឋានCRM ត្រូវរៀបចំបញ្ជីឈ្មោះ និងលិខិតអញ្ជើញអ្នកចូលរួមកិច្ចប្រជុំ PAB ដែលនឹងប្រារព្ធធ្វើ នៅថ្ងៃទី៣០ ខែមិថុនា ២០១៥ អោយបានមុនថ្ងៃទី ១៦-១៧ ខែមិថុនា ឆ្នាំ២០១៥នេះ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង ១០:១០ នាទីព្រឹក ថ្ងៃ ខែ ឆ្នាំ ដដែល ប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាល ជាទីបំផុត។

ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០១៥

ឯកភាពនិងគោរពជូនឯ.ឧ.អគ្គលេខា ពិនិត្យសំរេច

មន្ត្រីទទួលបន្ទុក

បានឃើញ និងឯកភាព

អគ្គលេខាធិការ

អគ្គលេខាធិការរងនិង

ជាប្រធាននាយកដ្ឋាន

**វេជ្ជ. រស់ សីលវ៉ាត់**

**ឯកឧត្តមវេជ្ជ. តែង គន្ធី**